# ឧបករណ៍ការសម្រេចចិត្តលើការពិនិត្យរកមើលជំងឺមហារីកសួត

## កូនសៀវភៅសង្ខេប

## តើឧបករណ៍នេះមានគោលបំណងដើម្បីអ្វី?

ឧបករណ៍នេះអាចជួយអ្នកក្នុងការសម្រេចចិត្តថាតើអ្នកចង់ចាប់ផ្តើមពិនិត្យរកមើលជំងឺមហារីកសួត ឬអត់។ មនុស្សជាច្រើនមើលឃើញពីអត្ថប្រយោជន៍នានា ហើយគិតថា ការពិនិត្យរកមើលជំងឺមហារីកគឺជារឿងល្អ។ មានវិធីជាច្រើនដែលការពិនិត្យអាចជួយអ្នកបាន ហើយមានរឿងជាច្រើនដែលអ្នកគួរដឹងមុនពេលអ្នកធ្វើការសម្រេចចិត្តដើម្បីធ្វើការពិនិត្យ។

កូនសៀវភៅនេះត្រូវបានរចនាឡើងដើម្បីផ្តល់ឱ្យអ្នកនូវព័ត៌មាន ដើម្បីជួយអ្នកធ្វើការសម្រេចចិត្តបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់ អំពីថាតើអ្នកចង់ធ្វើការពិនិត្យឬអត់។ នេះជាជម្រើសរបស់អ្នក – គ្មានចម្លើយត្រូវ ឬខុសអំពីថាតើត្រូវមានការពិនិត្យឬអត់នោះទេ។

## តើជំងឺមហារីកសួតជាអ្វី?

ជំងឺមហារីកសួតគឺជាជំងឺមហារីកមួយដែលចាប់ផ្តើមនៅក្នុងសួត។ កោសិកាមួយក្រុមដែលមិនមានលក្ខណៈធម្មតា ហើយលូតលាស់ដែលមិនអាចគ្រប់គ្រងបាន ហើយក៏អាចរីករាលដាលទៅផ្នែកផ្សេងទៀតនៃរាងកាយផងដែរ។

## តើការពិនិត្យរកមើលជំងឺមហារីកសួតជាអ្វី?

ការពិនិត្យរកមើលជំងឺមហារីកសួត ពាក់ព័ន្ធនឹងការស្កេនដោយកុំព្យូទ័រថតរូបភាពកាំរស្មីអ៊ិចដូសកម្រិតទាប (CT) (CT ដូសកម្រិតទាប) សម្រាប់មនុស្សដែលមិនមានរោគសញ្ញា (ឧទាហរណ៍ អ្នកមិនមានក្អកជាប់រហូត ឬមិនក្អកមានឈាម) ដើម្បីរកមើលសញ្ញានានានៃជំងឺមហារីកនៅដំណាក់កាលដំបូង។ ការរកឃើញជំងឺមហារីកសួតនៅដំណាក់កាលដំបូង បង្កើនជម្រើសនៃការព្យាបាល និងផ្តល់ឱ្យអ្នកនូវឱកាសនៃការព្យាបាលកាន់តែប្រសើរឡើង

ការស្កេន CT ដូសកម្រិតទាបសម្រាប់ការពិនិត្យជំងឺមហារីកសួតគឺឥតគិតថ្លៃសម្រាប់អ្នកដែលមាន Medicare។

## តើខ្ញុំមានសិទ្ធិទទួលទេ?

អ្នកមានសិទ្ធិទទួលបានកម្មវិធីនេះ ប្រសិនបើអ្នកបំពេញតាមលក្ខណៈវិនិច្ឆ័យទាំងអស់ខាងក្រោម៖

**មានអាយុពី 50 ទៅ 70 ឆ្នាំ**

និង

**មិនមានរោគសញ្ញា ឬសញ្ញានានាដែលបង្ហាញថាកើតជំងឺមហារីកសួត**
(ឧទាហរណ៍ ក្អកជាប់រហូតមិនអាចពន្យល់បាន ក្អកមានឈាម ដង្ហើមខ្លីដោយគ្មានមូលហេតុ)។

និង

**ជក់បារី ឬមានប្រវត្តិជក់បារី**
(ឈប់ជក់ក្នុងរយៈពេល 10 ឆ្នាំ)

និង

**មានប្រវត្តិជក់បារីយ៉ាងហោចណាស់ 30 កញ្ចប់ឆ្នាំ**
(ឧទាហរណ៍ មួយកញ្ចប់ក្នុងមួយថ្ងៃរយៈពេល 30 ឆ្នាំ ឬ 2 កញ្ចប់ក្នុងមួយថ្ងៃសម្រាប់រយៈពេល 15 ឆ្នាំ)

**សូមពិភាក្សាជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក ដើម្បីមើលថាតើអ្នកមានសិទ្ធិទទួលដែរឬទេ។**

## តើការពិនិត្យរកមើលជំងឺមហារីកសួតអាចជួយខ្ញុំបានដោយរបៀបណា?

- ស្វែងរកជំងឺមហារីកសួតនៅដំណាក់កាលដំបូង។ មានជម្រើសព្យាបាលច្រើនជាងមុន និងឱកាសល្អប្រសើរក្នុងការព្យាបាលនៅពេលជំងឺមហារីកត្រូវបានរកឃើញនៅដំណាក់កាលដំបូង។
- ផ្តល់ភាពស្ងប់ចិត្តអំពីសុខភាពសួតរបស់អ្នក។
- ផ្តល់ឱកាសដើម្បីពិភាក្សាអំពីប្រវត្តិនៃការជក់បារី និងទទួលបានការគាំទ្រ ប្រសិនបើអ្នកជ្រើសរើសផ្តាច់បារី។

## តើមានអ្វីទៀតដែលខ្ញុំគួរដឹងអំពីការពិនិត្យរកមើលជំងឺមហារីកសួតទេ?

- ភាពវិជ្ជមានមិនពិត (ឧទាហរណ៍ លទ្ធផលស្កេនបង្ហាញថាអ្នកអាចមានជំងឺមហារីក ប៉ុន្តែការស៊ើបអង្កេតបន្តនិយាយថាអ្នកមិនមាន) អាចកើតឡើងជាមួយនឹងការពិនិត្យ ឬការធ្វើតេស្តវេជ្ជសាស្ត្រណាមួយ។
- ការធ្វើរោគវិនិច្ឆ័យលើសកំណត់អាចកើតឡើងជាមួយនឹងការពិនិត្យ ឬការធ្វើតេស្តវេជ្ជសាស្ត្រណាមួយ។
- អ្នកអាចត្រូវបានប៉ះពាល់នឹងបរិមាណតិចតួចនៃវិទ្យុសកម្ម។
- ការពិនិត្យអាចរកឃើញរបកគំហើញបន្ថែមដែលមិនទាក់ទងនឹងជំងឺមហារីកសួត។

Australian Government

NATIONAL LUNG CANCER SCREENING PROGRAM

| សំណួរសំខាន់ៗ | ការពិនិត្យ | គ្មានការពិនិត្យ |
| --- | --- | --- |
| តើឱកាសនៃការរកឃើញជំងឺមហារីកសួតនៅដំណាក់កាលដំបូងមានអ្វីខ្លះ? | ជំងឺមហារីកសួត 70 ក្នុងចំណោមជំងឺមហារីកសួត 100 នឹងត្រូវបានរកឃើញនៅដំណាក់កាលដំបូងទី [1]។ | ជំងឺមហារីកសួត 7 ក្នុងចំណោមជំងឺមហារីកសួត 100 នឹងត្រូវបានរកឃើញនៅដំណាក់កាលដំបូងទី[1]។ |
| តើមានឱកាសអ្វីខ្លះដែលលទ្ធផលនៃការស្កេនបង្ហាញថាកើតជំងឺមហារីកសួត ប៉ុន្តែការស៊ើបអង្កេតតាមដានប្រាប់ថាអ្នកមិនមានជំងឺមហារីកសួតទេ? | ក្នុងចំណោមមនុស្សទាំងអស់ដែលត្រូវបានពិនិត្យ ប្រហែល 3 នាក់ក្នុងចំណោម 100 នាក់នឹងមានដុំពកតូចដែលមានហានិភ័យខ្ពស់ ឬហានិភ័យខ្ពស់ខ្លាំងដែលត្រូវបានរកឃើញ1។ ដើម្បីមើលថាតើដុំពកតូចនោះដែលមានហានិភ័យខ្ពស់ ឬហានិភ័យខ្ពស់ខ្លាំងជាជំងឺមហារីក អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកអាចស្នើឱ្យមានការស៊ើបអង្កេតបន្ថែមទៀត។ តិចជាងពាក់កណ្តាលនៃអ្នកដែលមានដុំពកតូចដែលមានហានិភ័យខ្ពស់ ឬហានិភ័យខ្ពស់ខ្លាំងនឹងមានមហារីកសួត។ | អ្នកដែលមិនមានការពិនិត្យនឹងជៀសវាងលទ្ធភាពនៃការធ្វើតេស្តវេជ្ជសាស្ត្រដែលមិនចាំបាច់ ប៉ុន្តែក៏នឹងមិនមានឱកាសរកឃើញជំងឺមហារីកសួតដំណាក់កាលដំបូងដែលគ្មានរោគសញ្ញាដែរ។ |
| តើមានឱកាសនៃការរកឃើញអ្វីផ្សេងទៀតក្រៅពីជំងឺមហារីកសួតនៅលើស្កេន? | ពេលខ្លះការស្កេននឹងរកឃើញអ្វីដែលត្រូវការធ្វើតេស្តបន្ថែមទៀត ហើយពេលខ្លះទៀតការស្កេននឹងរកឃើញជំងឺធ្ងន់ធ្ងរផ្សេងទៀតដែលត្រូវការការព្យាបាល។ ការព្យាបាលទាំងនេះអាចជួយសង្គ្រោះជីវិតរបស់អ្នក។ | អ្នកដែលមិនមានការពិនិត្យ ជៀសវាងការធ្វើតេស្តផ្នែកវេជ្ជសាស្ត្របន្ថែម ប៉ុន្តែក៏នឹងមិនមានឱកាសរកឃើញមានស្ថានភាពសុខភាពផ្សេងទៀតដែលអាចព្យាបាលបាននៅដំណាក់កាលដំបូងផងដែរ។ |

1 ផ្អែកលើការប៉ាន់ស្មានដ៏ល្អបំផុតពីការសាកល្បងដែលគ្រប់គ្រងដោយចៃដន្យ។

# ឧបករណ៍ការសម្រេចចិត្ត

សូមចាំថា ការចូលរួមក្នុងការពិនិត្យរកមើលជំងឺមហារីកសួត គឺជាជម្រើសរបស់អ្នក។ ប្រើឧបករណ៍នេះខាងក្រោមដើម្បីជួយអ្នកក្នុងការសម្រេចចិត្តថាអ្វីដែលសំខាន់សម្រាប់អ្នក។

| សួរខ្លួនឯង៖ តើអ្វីសំខាន់សម្រាប់អ្នកនៅពេលសម្រេចចិត្តដើម្បីពិនិត្យរកមើលជំងឺមហារីកសួត? | គ្មានការពិនិត្យ មិនសំខាន់ ⟷ | | | | ការពិនិត្យ ⟷ សំខាន់ខ្លាំងណាស់ |
| --- | --- | --- | --- | --- | --- |
| ការរកឃើញជំងឺមហារីកសួតនៅដំណាក់កាលដំបូង មុនកើតមានរោគសញ្ញានានា?<br>(ឧ. ក្អកជាប់រហូត ដែលមិនអាចពន្យល់បាន ឬក្អកមានឈាម) | ☐ 1 | ☐ 2 | ☐ 3 | ☐ 4 | ☐ 5 |
| ការរកឃើញជំងឺមហារីកសួតនៅដំណាក់កាលដំបូង នៅពេលមានជម្រើសក្នុងការព្យាបាលកាន់តែច្រើន? | ☐ 1 | ☐ 2 | ☐ 3 | ☐ 4 | ☐ 5 |
| ភាពស្ងប់ចិត្តអំពីសុខភាពសួតរបស់អ្នក? | ☐ 1 | ☐ 2 | ☐ 3 | ☐ 4 | ☐ 5 |
| មានឱកាសពិភាក្សាអំពីប្រវត្តិនៃការជក់បារី និងទទួលបានការគាំទ្រដើម្បីផ្តាច់បារី? | ☐ 1 | ☐ 2 | ☐ 3 | ☐ 4 | ☐ 5 |

| សួរខ្លួនឯង៖ តើអ្នកព្រួយបារម្ភយ៉ាងណាដែរចំពោះ៖ | គ្មានការពិនិត្យ ព្រួយបារម្ភខ្លាំង ⟷ | | | | ការពិនិត្យ ⟷ មិនបារម្ភ |
| --- | --- | --- | --- | --- | --- |
| កំពុងព្រួយបារម្ភអំពីការចូលរួមក្នុងការពិនិត្យរកមើលជំងឺមហារីកសួត? | ☐ 5 | ☐ 4 | ☐ 3 | ☐ 2 | ☐ 1 |
| កំពុងត្រូវបានប៉ះពាល់នឹងវិទ្យុសកម្ម? | ☐ 5 | ☐ 4 | ☐ 3 | ☐ 2 | ☐ 1 |
| មានភាពវិជ្ជមានមិនពិត?<br>(ឧទាហរណ៍ លទ្ធផលស្កេនបង្ហាញថាអ្នកអាចមានជំងឺមហារីក ប៉ុន្តែការស៊ើបអង្កេតបន្តនិយាយថាអ្នកមិនមាន) | ☐ 5 | ☐ 4 | ☐ 3 | ☐ 2 | ☐ 1 |
| ការធ្វើតេស្តផ្សេងទៀតដើម្បីស៊ើបអង្កេតរបកគំហើញណាមួយពីការស្កេន CT ដូសកម្រិតទាប? | ☐ 5 | ☐ 4 | ☐ 3 | ☐ 2 | ☐ 1 |

### សូមក្រឡេកមើលចម្លើយរបស់អ្នកខាងលើ

ប្រសិនបើចម្លើយរបស់អ្នកភាគច្រើននៅខាងស្តាំ នោះអ្នកពេញចិត្តនឹងការពិនិត្យ។
ប្រសិនបើចម្លើយរបស់អ្នកភាគច្រើននៅខាងឆ្វេង នោះអ្នកពេញចិត្តនឹងការមិនពិនិត្យទេ

**សម្រាប់ព័ត៌មានបន្ថែមអំពីកម្មវិធីពិនិត្យរកមើលជំងឺមហារីកសួតថ្នាក់ជាតិ៖**

www.health.gov.au/nlcsp

Quitline 13 7848

**សម្រាប់ជំនួយក្នុងការផ្តាច់បារី៖**

www.quit.org.au

DT0004838_0625

ធនធាននេះត្រូវបានបង្កើតឡើងនៅសាកលវិទ្យាល័យស៊ីដនីដោយមានមូលនិធិពីសមាគមអន្តរជាតិសម្រាប់ការសិក្សាជំងឺមហារីកសួត (IASLC) ហើយបានកែសម្រួលនៅសាកលវិទ្យាល័យមែលប៊នជាមួយនឹងការផ្តល់មូលនិធិពីរដ្ឋាភិបាលអូស្ត្រាលី។

កំណត់ឡើងវិញ